**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៧០ . អនក្រ . បក**

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតក្រុមប្រឹក្សាភិបាលបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា ១.-**

បង្កើតក្រុមប្រឹក្សាភិបាលបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស (Manpower Training and Oversea Sending Board; MTOSB) ដែលជាស្ថាប័នសាធារណៈ (រដ្ឋ) សម្រាប់ជ្រើសរើស បណ្តុះបណ្តាល

បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបរទេស។ ក្រុមប្រឹក្សាភិបាលនេះ មានទីតាំងស្ថិតនៅក្នុងវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (National Polytechnic Institute of Cambodia; NPIC) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា ២.-**

ក្រុមប្រឹក្សាភិបាលនេះមានភារកិច្ចដូចខាងក្រោម :

- ទំនាក់ទំនងជាមួយប្រទេសដែលទទួលពលករដើម្បីក្តាប់ព័ត៌មាន និងតម្រូវការទីផ្សារការងារ ហើយដោះស្រាយឱ្យបានទាន់ពេលវេលា
- សម្របសម្រួលឱ្យបានជិតស្និទ្ធជាមួយស្ថាប័នពាក់ព័ន្ធក្នុងប្រទេស ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការជ្រើសរើស បណ្តុះបណ្តាល បញ្ជូននិងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបរទេស
- កសាងបទដ្ឋាន លក្ខណៈវិនិច្ឆ័យ និងនិតិវិធីឱ្យបានគ្រប់ជ្រុងជ្រោយក្នុងការជ្រើសរើស និងអប់រំបណ្តុះបណ្តាល ដើម្បីបំពេញសំណូមពរ និងលក្ខខណ្ឌរបស់ប្រទេសជាដៃគូប្រកបដោយតម្លាភាព
- រៀបចំ និងចាត់ចែងបែបបទបញ្ជូន និងគ្រប់គ្រងពលករដែលទៅធ្វើការនៅក្រៅប្រទេសរហូតដល់ត្រឡប់មកមាតុប្រទេសវិញ។

**មាត្រា ៣.-**

ក្រុមប្រឹក្សាភិបាលនេះមានសមាសភាពដូចតទៅ :

| | |
|---|---|
| - រដ្ឋលេខាធិការទទួលបន្ទុកការងារ មុខរបរ និងហត្ថពលកម្ម និងជាប្រធានក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា | ប្រធាន |
| - អនុរដ្ឋលេខាធិការទទួលបន្ទុកការងារ មុខរបរ និងហត្ថពលកម្ម | អនុប្រធាន |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | សមាជិក |

សមាសភាពនៃក្រុមប្រឹក្សានេះ ត្រូវតែងតាំងដោយអនុក្រឹត្យ។

**មាត្រា ៤.-**

- ក្រុមប្រឹក្សាភិបាលនេះមានអង្គភាពបីស្ថិតនៅក្រោមចំណុះ :
  - អង្គភាពរដ្ឋបាល និងហិរញ្ញវត្ថុ
  - អង្គភាពជ្រើសរើស និងបណ្តុះបណ្តាល
  - អង្គភាពបញ្ជូន និងគ្រប់គ្រងពលករ
- ក្រុមប្រឹក្សាភិបាលនេះអាចបង្កើតអង្គភាពផ្សេងៗទៀតក្រោមចំណុះបានតាមការចាំបាច់

- អង្គភាពនីមួយៗដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់
- រចនាសម្ព័ន្ធ ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពចំណុះក្រុមប្រឹក្សាភិបាលបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ៥.~**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦.~**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល :*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *ឯកសារ-កាលប្បវត្តិ*

## ឧបសម្ព័ន្ធនៃអនុក្រឹតលេខ...៧០ អនក្រ.បក...ចុះថ្ងៃទី...២៥...ខែ...កក្កដា.....ឆ្នាំ...២០០៦...

## អង្គការលេខរបស់ក្រុមប្រឹក្សាភិបាលបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស

